# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្ដារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 18-May-21, 13:49
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**:

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

# សេចក្ដីសង្ខេបរបស់មេធាវីការពារក្ដី
# លើបែបបទនៃសវនាការបណ្ដឹងសាទុក្ខ

---

ដាក់ដោយ៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

ដាក់ជូន៖

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រីម

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Florence Ndepele MWACHANDE-MUMBA

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

លោក តាន់ ឆាយរ័ត្ន

កញ្ញា Mathilde CHIFFERT

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម Maureen HARDING CLARK

ចៅក្រម យ៉ា ណារិន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោកស្រី Brenda J. HOLLIS

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

១. នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ អង្គជំនុំជម្រះតុលាការកំពូលបានជូនដំណឹងអំពីការសម្រេចលើកពេលសវនាការបណ្តឹងសាទុក្ខ ដោយគ្មានកាលកំណត់ "ដោយសារស្ថានភាពបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា (ពាក់ព័ន្ធនឹងជំងឺកូវីដ-១៩")[1]។

២. នៅថ្ងៃដដែលនោះ ការិយាល័យរដ្ឋបាលបានដាក់ចម្លើយតបទៅនឹងសំណើសុំលើកពេលសវនាការរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") អមដោយរបាយការណ៍ស្តីពីពិធីសារ និងវិធានការការពារជំងឺកូវីដ-១៩ ដើម្បីធានាឲ្យសវនាការដំណើរការទៅដោយសុវត្ថិភាព ("របាយការណ៍")[2]។

៣. នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ សហព្រះរាជអាជ្ញាបានដាក់សេចក្តីសង្កេត និងសំណើ ផ្អែកលើចម្លើយតបរបស់ការិយាល័យរដ្ឋបាល និងរបាយការណ៍[3]។ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ សហមេធាវីនាំមុខបានផ្ញើជូនភាគីនូវសេចក្តីសង្កេតរបស់ខ្លួនលើបែបបទនៃសវនាការ និងចម្លើយតបទៅនឹងសេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា[4]។

---

[1] ការជូនដំណឹងអំពីសវនាការបណ្តឹងសាទុក្ខសំណុំរឿង ០០២/០២ អនុលោមតាមវិធាន ១០៨(៣) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ ឯកសារ **F62** (ជូនដំណឹងតែជាភាសាអង់គ្លេសប៉ុណ្ណោះ)។

[2] ចម្លើយតបរបស់ការិយាល័យរដ្ឋបាលទៅនឹងសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឲ្យពន្យារពេលសវនាការបណ្តឹងសាទុក្ខដែលគ្រោងធ្វើនៅថ្ងៃទី១៧-២១ ខែឧសភា ឆ្នាំ២០២១ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ ឯកសារ **F61/3** ("ចម្លើយតបរបស់ការិយាល័យរដ្ឋបាល"), ឧបសម្ព័ន្ធ គ - ពិធីសារ និងវិធានការការពារជំងឺកូវីដ-១៩ ពុំមានចុះកាលបរិច្ឆេទ ឯកសារ **F61/3.4** ("របាយការណ៍")។

[3] សេចក្តីសង្កេត និងសំណើរបស់សហព្រះរាជអាជ្ញា ផ្អែកលើចម្លើយតបរបស់ការិយាល័យរដ្ឋបាល ទៅនឹងសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំពន្យារពេលសវនាការលើបណ្តឹងសាទុក្ខ ដែលគ្រោងនឹងធ្វើនៅថ្ងៃទី១៧-២១ ខែឧសភា ឆ្នាំ២០២១ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ ឯកសារ **F61/3/1** ("សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា") ជូនដំណឹងជាភាសាអង់គ្លេស និងខ្មែរ នៅថ្ងៃទី០៥ ខែឧសភា និងជាភាសាបារាំង នៅថ្ងៃទី១២ ខែឧសភា។

[4] សេចក្តីសង្កេតរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី លើបែបបទនៃសវនាការ និងចម្លើយតបទៅនឹងសេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា ផ្ញើជូនតាមអ៊ីម៉ែល នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ ដោយរង់ចាំការបកប្រែជាភាសាខ្មែរ ដើម្បីដាក់ជូនអង្គជំនុំជម្រះតុលាការកំពូល ("សេចក្តីសង្កេតរបស់សហមេធាវីនាំមុខ")។ មេធាវីការពារក្តីសូមយោងលើឯកសារនេះ ដោយរង់ចាំការបកប្រែជាភាសាខ្មែរ និងបារាំង។

៤. តាមរយៈសារណានេះ មេធាវីការពារក្ដីលោក ខៀវ សំផន ("មេធាវីការពារក្ដី") សូមផ្ដល់ជូននូវសេចក្ដីសង្កេតលើបែបបទនៃសវនាការនាពេលខាងមុខ ក្រោយពីបានផ្លាស់ប្ដូរយោបល់ជាមួយលោក ខៀវ សំផន៖ សេចក្ដីសង្កេតបឋមខ្លះៗលើការរៀបចំសវនាការ (ផ្នែកទី ១) សេចក្ដីសង្កេតលើវិធានការបង្ការដែលត្រូវអនុវត្ត (ផ្នែកទី ២) និងសេចក្ដីសង្កេតលើការកំណត់កាលបរិច្ឆេទនៃសវនាការ (ផ្នែកទី ៣)។

## ផ្នែកទី ១. សេចក្ដីសង្កេតបឋមលើការរៀបចំសវនាការ

៥. ជាបឋម មេធាវីការពារក្ដីសូមគូសបញ្ជាក់ថា សំណូមពរពីររបស់ការិយាល័យរដ្ឋបាលមិនមែនជាជម្រើសទេ ពីព្រោះពុំមានមូលដ្ឋាន នៅក្នុងក្របខ័ណ្ឌគតិយុត្តិជាធរមាន នៅ អ.វ.ត.ក។

៦. លទ្ធភាពដែលបានលើកឡើង ពាក់ព័ន្ធនឹងសវនាការ "តាមប្រព័ន្ធអ៊ីនធឺណែតទាំងស្រុង"[5] ពុំមានចែងនៅក្នុងវិធានផ្ទៃក្នុង ឬក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឡើយ។

៧. ចំពោះលទ្ធភាពនៃការធ្វើ "សេចក្ដីសន្និដ្ឋានផ្ទាល់មាត់ [ដែល] អាចត្រូវបានជំនួសដោយកិច្ចដំណើរការជាលាយលក្ខណ៍អក្សរ ដើម្បីឱ្យស្របទៅនឹងរយៈពេលដែលបានគណនា សម្រាប់សំណុំរឿងនាពេលបច្ចុប្បន្ន និងការរំពឹងទុករបស់សាធារណជន"[6] គឺផ្ទុយនឹងបទប្បញ្ញត្តិស្ដីពីការតម្រូវជាចាំបាច់ឱ្យមានសវនាការបណ្ដឹងសាទុក្ខ[7]។

---

[5] ចម្លើយតបរបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ៥។

[6] ចម្លើយតបរបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ៤។

[7] វិធាន ១០៩(១) នៃវិធានផ្ទៃក្នុង (អង្គជំនុំជម្រះតុលាការកំពូលអាចធ្វើសេចក្ដីសម្រេចពិចារណាលើបណ្ដឹងសាទុក្ខភ្លាមៗ ដោយផ្អែកតែលើមូលដ្ឋាននៃសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដែលដាក់ដោយភាគីតែប៉ុណ្ណោះ។ ដូច្នេះ ក្នុងករណីបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម អង្គជំនុំជម្រះតុលាការកំពូលមិនអាចធ្វើបែបនេះបានឡើយ)។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៣៨៨ ដល់មាត្រា ៣៩៥ ពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍ និងមាត្រា ៤៣៣ ដល់មាត្រា ៤៣៤ ពាក់ព័ន្ធនឹងបណ្ដឹងសាទុក្ខ (មាត្រា ៤៣៤ វាក្យខណ្ឌ ៥៖ ("នៅក្នុងគ្រប់ករណី តុលាការកំពូលមិនអាចពិភាក្សាសម្រេចលើរឿងណាមួយ ដោយគ្មានធ្វើការពិភាក្សាដេញដោលនៅពេលសវនាការ")។

៨. លើសពីនេះទៅទៀត លទ្ធភាពនេះនឹងមិនអាចឲ្យគោរពតាមកាលវិភាគ និងការរំពឹងទុករបស់សាធារណជនបានទេ។ វាមិនត្រឹមតែដកហូតពីលោក ខៀវ សំផន នូវសិទ្ធិក្នុងការនិយាយ ចំពោះមុខចៅក្រម និងសាធារណជនប៉ុណ្ណោះទេ[8] ថែមទាំងនាំឲ្យអូសបន្លាយពេលវេលាឲ្យកាន់តែយូរទៅទៀត។ ជាក់ស្តែង ការជំនួសសវនាការដោយនីតិវិធីជាលាយលក្ខណ៍អក្សរ គឺស្មើនឹងដាក់ (និងបកប្រែជាពីរភាសា)៖

- សារណាពីគ្រប់ភាគីទាំងអស់ ដើម្បីឆ្លើយទៅនឹងសំណួររបស់អង្គជំនុំជម្រះតុលាការកំពូល
- សារណាពីសហព្រះរាជអាជ្ញា ដើម្បីឆ្លើយតបទៅនឹងចម្លើយតបរបស់មេធាវីការពារក្តី (៣០ ទំព័រ) ទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា
- សារណាពីមេធាវីការពារក្តី ដើម្បីឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា (៦៣៧ ទំព័រ) និងសហមេធាវីនាំមុខ (៣៥៤ ទំព័រ) ទៅនឹងបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី[9]។

៩. ផ្ទុយទៅវិញ មេធាវីការពារក្តី ដែលមានបន្ទុកការងារធ្ងន់ធ្ងរជាងគេ មានមធ្យោបាយតិចតួចបំផុត។ ក្រោយពីដាក់សារណាបណ្តឹងសាទុក្ខ ការិយាល័យរដ្ឋបាលបានអនុញ្ញាតឲ្យមេធាវីទាំងពីររូបធ្វើការតែកន្លះថ្ងៃ និងមានជំនួយការតែពីរនាក់ប៉ុណ្ណោះ។ ជាក់ស្តែង ការិយាល័យរដ្ឋបាលបានបដិសេធសំណើសុំបុគ្គលិកបន្ថែម ចាប់ពីពេលដាក់សារណាតបរបស់ភាគីផ្សេងទៀត។ ទាល់តែនៅខែកុម្ភៈ ទើបមេធាវីបានចូលធ្វើការពេញម៉ោងឡើងវិញ និងទទួលបានជំនួយការពីរនាក់ថែមទៀត ចាប់ពីខែមីនា សម្រាប់រយៈពេលបីខែ ដោយមិនអាចបន្តកិច្ចសន្យាការងារជាថ្មីបាន (គឺផុតកំណត់នៅខែឧសភា)។ ក្នុងលក្ខខណ្ឌបែបនេះ ដូចសហព្រះរាជអាជ្ញាបានលើកឡើង[10] ច្បាស់ណាស់ថា មេធាវីការពារក្តីត្រូវការពេលវេលាច្រើន ដើម្បីរៀបចំសារណារបស់ខ្លួន។ ទោះជាយ៉ាងនេះក្តី សារណាទាំងនេះមិនអាចឲ្យរួចផុតពីការធ្វើសវនាការឡើយ។

## ផ្នែកទី ២. សេចក្តីសង្ខេបលើវិធានការបន្ទាន់សម្រាប់សវនាការ

[8] វិធាន ១០៩(១) នៃវិធានផ្ទៃក្នុង ("សវនាការនៃអង្គជំនុំជម្រះតុលាការកំពូលត្រូវធ្វើឡើងជាសាធារណៈ"), វិធាន ១០៩(៦) ("គ្រប់ករណីទាំងអស់ ជនជាប់ចោទត្រូវនិយាយក្រោយគេបំផុត។ មេធាវីរបស់ជនជាប់ចោទត្រូវបានអនុញ្ញាតឲ្យធ្វើសេចក្តីសន្និដ្ឋានតបដោយសង្ខេប")។ សូមមើលសេចក្តីសង្កេតរបស់សហមេធាវីនាំមុខ កថាខណ្ឌ ៦១។

[9] ចំនួនទំព័រជាភាសាបារាំង។

[10] សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៣(៤)។

១០. អ្នកសរសេររបាយការណ៍ ដែលផ្ដល់ជូនដោយការិយាល័យរដ្ឋបាល បានណែនាំឱ្យមានការរៀបចំខាងសម្ភារៈនៅក្នុងសាលសវនាការ និងចាត់វិធានការបង្ការ។ មេធាវីការពារក្ដីមិនមានការបណ្ដុះបណ្ដាលខាងវេជ្ជសាស្ត្រ ឬខាងរោគរាតត្បាតទេ ហើយក៏គ្មានលទ្ធភាពអ្វីទៅផ្ដល់មតិយោបល់លើសេចក្ដីណែនាំទាំងនេះឡើយ ដែលទំនងជាសមហេតុផលហើយ។ ប៉ុន្តែ មេធាវីការពារក្ដីសូមរម្លឹកអំពីការពិចារណាតាមផ្លូវច្បាប់មួយចំនួនពាក់ព័ន្ធនឹងវត្តមានរបស់អ្នកចូលរួម (២.១) និងស្នើឡើងនូវវិធានការបង្ការបន្ថែម ដើម្បីបង្កភាពងាយស្រួល (២.២)។

## ២.១. <u>សេចក្ដីសង្កេតលើការកម្រិតចំនួនមនុស្សនៅក្នុងសាលសវនាការ និងវត្តមានលោក ខៀវ សំផន</u>

១១. វិធានការចម្បងមួយដែលបានណែនាំឡើង នៅក្នុងរបាយការណ៍ គឺការកម្រិតចំនួនមនុស្សដែលមានវត្តមាននៅក្នុងសាលសវនាការ ដែលត្រូវរក្សាចំនួនដដែល សម្រាប់រយៈពេលសវនាការទាំងមូល "ដើម្បីបង្កើតជារបាំង"។ របាយការណ៍បានផ្ដល់អនុសាសន៍ឱ្យ ៤ នាក់មួយភាគី មានវត្តមាននៅក្នុងសាលសវនាការ ហើយជនជាប់ចោទមានវត្តមាន យ៉ាងយូរបំផុត ១៥ នាទី ដើម្បីបង្ហាញខ្លួនដល់ចៅក្រម[11]។

១២. សហព្រះរាជអាជ្ញាមិន "យល់ស្រប" ជាមួយការកំណត់ចំនួនអ្នកចូលរួមពីការិយាល័យរបស់ខ្លួនត្រឹម ៤ នាក់ នៅក្នុងសាលសវនាការ[12] ដែល "មិនស៊ីសង្វាក់" នឹងរបៀបដែលសហព្រះរាជអាជ្ញាបានកំណត់ថាអាច "ត្រៀមរៀបចំខ្លួន និងបង្ហាញការដេញដោលដោយផ្ទាល់មាត់បានល្អបំផុត"[13]។ ដោយសារទំហំ និងភាពស្មុគស្មាញនៃសំណុំរឿង សហព្រះរាជអាជ្ញាបានគ្រោងអ្នកចូលរួមចំនួន ៧ នាក់ ឬអាចដល់ ៨ នាក់ តាងនាមអយ្យការ ដែលបានធ្វើការលើចំណុចជាក់លាក់រៀងៗខ្លួន[14]។ សហព្រះរាជអាជ្ញាស្នើសុំឱ្យមនុស្ស ៦ នាក់ មានវត្តមាននៅក្នុងសាលសវនាការ ក្នុងពេលជាមួយគ្នា

[11] របាយការណ៍ ទំព័រ ២ និង ៦ ERN 01669044 និង ERN 01669048។

[12] សេចក្ដីសង្កេតរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤-៧។

[13] សេចក្ដីសង្កេតរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២។

[14] សេចក្ដីសង្កេតរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥។

និងអាចធ្វើការប្តូរវេនគ្នា តាមវគ្គសវនាការ និងថ្ងៃនីមួយៗ ដោយបញ្ជាក់ថាអ្នកចូលរួមនឹងផ្លាស់ប្តូរយោបល់ជាមួយបុគ្គលិកផ្សេងទៀតនៅក្នុងការិយាល័យរបស់ខ្លួន និងធ្វើដំណើរ យ៉ាងហោចណាស់រវាងផ្ទះរបស់ពួកគេ និងតុលាការ ជារៀងរាល់ថ្ងៃនៃសវនាការ[15]។

១៣. ដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំតុលាការកំពូលបញ្ជាឱ្យធ្វើកោសល្យវិច្ច័យពេញលេញបន្ថែមទៀតជាពិសេសដើម្បីអនុញ្ញាតឱ្យមានវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងបន្ទប់សវនាការ។[16] ពួកគាត់ យល់ស្របនឹងការិយាល័យសហព្រះរាជអាជ្ញាចំពោះការផ្តល់លទ្ធភាពឱ្យសមាជិកនៃក្រុមមេធាវីរបស់ពួកគាត់អាចប្តូរវេនគ្នាបាន នៅក្នុងពេលធ្វើសវនាការនីមួយៗ។[17] ដើមបណ្តឹងរដ្ឋប្បវេណី រំលឹកថាវត្តមាន និងសុវត្ថិភាពរបស់ ខៀវ សំផន នៅក្នុងពេលសវនាការ មានសារៈសំខាន់ណាស់សម្រាប់ពួកគាត់។[18]

១៤. មេធាវីការពារក្តីមិនយល់ស្របនឹងការដែលថាសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីមានការលំបាកក្នុងការកម្រិតចំនួនអ្នកចូលរួមក្នុងបន្ទប់សវនាការដូចដែលណែនាំឱ្យធ្វើនៅក្នុងរបាយការណ៍។ ជាក់ស្តែង ចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១[19] ខាងមុខនេះទៅ ក្រុមមេធាវីការពារក្តីនឹងត្រូវកាត់បន្ថយបុគ្គលិកខ្លួនជាអប្បបរមាវិញ គឺនឹងមានតែមេធាវី ២ នាក់ និងអ្នកប្រឹក្សាច្បាប់ ២ នាក់តែប៉ុណ្ណោះ បើពុំមានសេចក្តីសម្រេចថ្មីណាមួយចេញដោយការិយាល័យរដ្ឋបាល។ ដូច្នេះ ក្រុមមេធាវីការពាក្តីនឹងមិនចាំបាច់ប្តូរវេនគ្នា ឬប្រាស្រ័យទាក់ទងជាមួយអ្នកណាផ្សេងក្រៅពីលោក ខៀវ សំផន នោះឡើយ។ តាមព្រឹត្តន័យ ក្រុមមេធាវីការពារក្តីនឹងស្ថិតនៅក្នុង "របាំងពពុះ" ដ៏តូចមួយស្រាប់បាត់ទៅហើយ។

១៥. ពិតណាស់ មេធាវីការពារក្តីយល់យ៉ាងច្បាស់ពីមូលហេតុដែលជម្រុញឱ្យសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី ជំទាស់នឹងអនុសាសន៍នៃរបាយការណ៍ស្តីពីវត្តមានរបស់ពួកគេនៅក្នុងបន្ទប់

---

[15] សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦, ៧, ១៣។

[16] សេចក្តីសង្កេតរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១៦-១៨, ៤១, ៦៧។

[17] សេចក្តីសង្កេតរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៤៤-៤៦។

[18] សេចក្តីសង្កេតរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៣៦។

[19] សូមមើលកថាខណ្ឌ៩ ខាងលើ។

សវនាការ ប៉ុន្តែមេធាវីការពារក្តីមានកាតព្វកិច្ចគូសបញ្ជាក់ថាការឆ្លើយតបជាវិជ្ជមានទៅនឹងសំណើរបស់ពួកគេ មិនត្រូវប៉ះពាល់ដល់ផលប្រយោជន៍របស់ ខៀវ សំផន និងវត្តមានរបស់គាត់នៅក្នុងបន្ទប់សវនាការជាដាច់ខាត។

១៦. គួរចងចាំថានេះគឺជាការកាត់ក្តី ខៀវ សំផន គឺមិនមែននរណាផ្សេងទៀតឡើយ។ នេះជាការប្តឹងឧទ្ធរណ៍របស់គាត់ប្រឆាំងនឹងការសម្រេចឱ្យគាត់ជាប់ពិរុទ្ធជាច្រើន និងការផ្តន្ទាទោសឱ្យគាត់ជាប់ពន្ធនាគារមួយជីវិត។ គាត់អាចខាតឬចំណេញច្រើនបំផុត ហើយខ្លាំងជាងអ្នកណាៗទាំងអស់។ គាត់មានសិទ្ធិយ៉ាងពេញលេញក្នុងការចូលរួមក្នុងការជំនុំជម្រះក្តីគាត់ និងសិទ្ធិទទួលបានការស្តាប់ពីបុព្វហេតុរបស់គាត់។ ចាប់តាំងពីឆ្នាំ២០១១ មក គាត់បានចូលរួមសវនាការដោយផ្ទាល់ ហើយស្របតាមលទ្ធភាពដែលត្រូវបានផ្តល់ឱ្យគាត់ គាត់កម្រចូលរួមពីបន្ទប់ឃុំខ្លួនបណ្តោះអាសន្ននៅខាងក្រោមបន្ទប់សវនាការណាស់ លើកលែងក្នុងករណីគាត់មានបញ្ហាសុខភាពម្តងម្កាលតែប៉ុណ្ណោះ។ ដូច្នេះ ប្រាកដណាស់ថាគាត់ចង់មានវត្តមាននៅក្នុងបន្ទប់សវនាការជាមួយក្រុមមេធាវីការពារក្តីសម្រាប់សវនាការចុងក្រោយ និងសំខាន់បំផុតនេះ។

១៧. សេចក្តីប៉ងប្រាថ្នារបស់សហព្រះរាជអាជ្ញាដើម្បីអាចរៀបចំ និងបង្ហាញការសង្កេតផ្ទាល់មាត់ឱ្យបានល្អបំផុត មិនអាចមានឧត្តមភាពលើវត្តមានរបស់ ខៀវ សំផន នៅក្នុងសវនាការឧទ្ធរណ៍របានឡើយ។ មួយវិញទៀត មេធាវីការពារក្តីសូមរំលឹកថាខ្លួនតែងតែបង្ខំចិត្តធ្វើការដោយមានបុគ្គលិកតិចជាងសហព្រះរាជអាជ្ញា ទោះបីជាសំណុំរឿងមានទំហំធំ និងស្មុគស្មាញក៏ដោយ ហើយខ្លួនពិតជាបង្ខំចិត្តសម្របខ្លួនទៅតាមស្ថានភាព បើទោះបីជាខ្លួនចង់មានលទ្ធភាពបំពេញការងារឱ្យបាន "ល្អបំផុត" ក៏ដោយ។ លើសពីនេះទៀត ការិយាល័យសហព្រះរាជអាជ្ញាជាអង្គភាពតែមួយ និងមិនអាចបំបែកបាន ពោលគឺសមាជិកនីមួយៗតំណាងឱ្យអង្គភាពទាំងមូល។ ដូច្នេះ សមាជិកទាំងអស់នៃអង្គភាពនេះអាចជំនួសគ្នាបាន។

១៨. ដូចគ្នានេះដែរ បើទោះជា ដូចដែលតុលាការកំពូលបានរំលឹក សិទ្ធិចូលរួមក្នុងការជំនុំជម្រះក្តីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជាសិទ្ធិដែលមិនអាចប្រកែកបានក៏ដោយ ក៏សិទ្ធិនេះ "ត្រូវតែគោរពតាម" សិទ្ធិរបស់ជនជាប់ចោទ និងការប្រព្រឹត្តទៅដោយរលូននៃការជំនុំជម្រះក្តី។[20]

១៩. ដូច្នេះ ប្រសិនបើមានការទទួលយកវិធានការណ៍ផ្សេងក្រៅពីវិធានការណ៍ដែលមានណែនាំក្នុងរបាយការណ៍ វិធានការណ៍ទាំងនេះត្រូវតែធ្វើឡើងយ៉ាងណាដើម្បីឱ្យ ខៀវ សំផន អាចចូលរួមតាមដានសវនាការក្នុងបន្ទប់សវនាការដោយផ្ទាល់ ហើយជាយថាហេតុ (ក្នុងពេលជាមួយគ្នា) ឬបន្ទាប់មកទៀត វាគប្បីឆ្លើយតបជាវិជ្ជមានដល់សំណើរបស់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។

២០. គឺក្នុងន័យនេះហើយដែលមេធាវីការពារក្តីស្នើឱ្យចាត់វិធានការបង្ការបន្ថែម។ ទោះជាយ៉ាងនេះក្តី ក្នុងករណីវេជ្ជបណ្ឌិតដែលតាមដានស្ថានភាពសុខភាព ខៀវ សំផន (ដែលទំនងជាមិនត្រូវបានពិគ្រោះដើម្បីធ្វើរបាយការណ៍នេះ) យល់ស្របថា ខៀវ សំផន មិនគួរមានវត្តមានក្នុងសាលសវនាការលើសពី ១៥ នាទី គាត់នឹងគោរពតាមអនុសាសន៍របស់វេជ្ជបណ្ឌិត និងតាមដានសវនាការពីបន្ទប់ឃុំខ្លួនបណ្តោះអាសន្ន។ ក្នុងករណីនេះ ខៀវ សំផន ចង់ប្រើប្រាស់ពេលវេលា ១៥ នាទី នៅក្នុងបន្ទប់សវនាការ ដើម្បីធ្វើសេចក្តីថ្លែងចុងក្រោយ ជាជាងការបង្ហាញវត្តមាននៅចំពោះមុខចៅក្រម។

## ២.២. <u>សំណើសុំវិធានការបង្ការបន្ថែម</u>

២១. សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី សង្កត់ធ្ងន់ថា អ្នកចូលរួមភាគច្រើននៅក្នុងសវនាការនឹងត្រូវបានចាក់វ៉ាក់សាំងមុនពេលបើកសវនាការ។ បើទោះជាវាកាត់បន្ថយហានិភ័យនៃការឆ្លងនិងការចម្លងវីរុសក៏ដោយ ក៏វានៅតែមានអាចបំបាត់បានទាំងស្រុងឡើយ។

---

[20] សេចក្តីណែនាំស្តីពីកិច្ចនីតិវិធីនៃសវនការ ចុះថ្ងៃទី ១៧ ខែមិថុនាឆ្នាំ ២០១៥ ឯកសារ F26 ទំព័រ ៤៖ "ដោយពិចារណាឃើញថា សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមសវនាការ ត្រូវគោរពតាមការរៀបចំសវនាការនៃកិច្ចដំណើរការនីតិវិធីឱ្យមានប្រសិទ្ធិភាព សិទ្ធិរបស់ជនជាប់ចោទ និងវិធានការការពារផ្សេងៗទៀតសម្រាប់សាក្សី ហេតុនេះការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសវនាការនេះ គឺអាស្រ័យលើទីកន្លែងទំនេរដែលមាននៅក្នុងបន្ទប់សវនាការ និងពុំត្រូវបានអនុញ្ញាតឡើយ ក្នុងករណីដែលមានដីកាបង្គាប់ឱ្យមានវិធានការការពារ ទាក់ទងនឹងសាក្សីណាមួយដែលបានកោះហៅនោះ"។

២២. មេធាវីការពារក្ដីយល់ថា វិធីល្អបំផុតដើម្បីធានាថាសវនាការដំណើរការដោយមានហានិភ័យអប្ប បរមា គឺត្រូវធ្វើ**តេស្តរអង់ទីហ្សែនរហ័ស**ទៅលើបុគ្គលដែលត្រូវចូលរួមក្នុងសាលសវនាការ នៅពេល ព្រឹករាល់មុនពេលចាប់ផ្ដើមសវនាការ (អាចដឹងលទ្ធផល ក្នុងរយៈពេល ១០ ទៅ ១៥ នាទី ក្រោយ)។

២៣. ប្រសិនបើសំណើនេះមិនអាចជាជំរើសទេ ការធ្វើតេស្តរហ័សគួរតែត្រូវបានអនុវត្តយ៉ាងតិច លើកទី ១ នៅពេលបុគ្គលម្នាក់ចូលបន្ទប់សវនាការជាលើកដំបូង និង ជាលើកទី២ លើអ្នកដែលមានវត្តមាន នៅក្នុងបន្ទប់សវនាការនៅថ្ងៃ ខៀវ សំផន ធ្វើសេចក្ដីថ្លែងជាចុងក្រោយ ក្នុងករណីដែលគាត់មាន វត្តមាននៅក្នុងបន្ទប់សវនាការនៅពេលធ្វើសេចក្ដីថ្លែងនេះ។

២៤. លើសពីនេះទៅទៀត រាល់បុគ្គលដែលមានវត្តមាននៅក្នុងបន្ទប់សវនាការ មិនត្រូវពាក់ម៉ាសពេទ្យវះ កាត់នោះទេ គឺត្រូវពាក់**ម៉ាស N-95** ដែលមានកម្រិតការពារខ្ពស់បំផុត។ ប្រសិនបើនេះមិនមែនជា ជម្រើសទេ ម៉ាសប្រភេទនេះគួរតែត្រូវបានផ្ដល់ឱ្យយ៉ាងហោចណាស់ដល់អ្នកដែលងាយរងគ្រោះ បំផុត ក្នុងចំណោមអ្នកទាំងនោះ មាន ខៀវ សំផន ម្នាក់ដែរ។ ក្នុងករណីណាក៏ដោយ គេគួរតែផ្លាស់ ប្ដូរម៉ាស រៀងរាល់៤ ម៉ោងម្ដង។

២៥. ម្យ៉ាងទៀត ដើម្បីរក្សា "របាំងពពុះ" តាមការណែនាំនៅក្នុងរបាយការណ៍ឱ្យហួសពីបន្ទប់សវនាការ សេវាកម្មតុលាការគួរតែសម្រួលការ "**ដឹកជញ្ជូនរបាំងពពុះ**" រហូតដល់តុលាការ សម្រាប់អ្នកដែល ត្រូវចូលបន្ទប់សវនាការ ជាក្រុមដោយឡែកៗ ដូចជាក្រុមតុលាការកំពូល និងអ្នកបកប្រែរបស់ខ្លួន ក្រុមសហព្រះរាជអាជ្ញា ក្រុមដើមបណ្ដឹងរដ្ឋប្បវេណី ក្រុមមេធាវីការពារក្ដី ក្រុមសន្តិសុខ ក្រុម បុគ្គលិកពេទ្យ ។ ប្រសិនបើសំណើនេះមិនអាចធ្វើទៅបាន មេធាវីការពារក្ដីដែលនឹងនៅជាប់ជាប្រចាំ ថ្ងៃជាមួយលោក ខៀវ សំផន នឹងព្យាយាមរៀបចំការដឹកជញ្ជូន "របាំងពពុះ" នេះ ដោយមធ្យោបាយ ផ្ទាល់ខ្លួន លើកលែងតែតុលាការកំពូលយល់ថា វាជាការប្រសើរជាងដែលទុកឱ្យខ្លួនរៀបចំកិច្ចការ នេះ។ ប្រាកដណាស់ មេធាវីការពារក្ដីក៏មានចេតនារឹតត្បិតទំនាក់ទំនងដោយផ្ទាល់ជាមួយអ្នកដទៃ ក្នុងអំឡុងពេលទាំងមូលនៃសវនាការ ហើយខ្លួនក៏ជឿជាក់ថាអ្នកចូលរួមទាំងអស់នឹងបង្ហាញពីការ ទទួលខុសត្រូវផ្ទាល់ខ្លួនខ្ពស់ផងដែរ។

២៦. ក្រៅពីសំណើសុំវិធានការបង្ការបន្ថែមដែលទើបតែបង្ហាញនេះ មេធាវីការពារក្តីទទូចសុំឱ្យគោរព ប្រកបដោយសីលធម៌ខ្ពង់ខ្ពស់នូវវិធានការណ៍ដែលមានណែនាំនៅក្នុងរបាយការណ៍ សម្រាប់បុគ្គល ទាំងឡាយដែលនឹងត្រូវប៉ះពាល់ ខៀវ សំផន (ដោយហេតុគាត់មិនអាចដើរដោយខ្លួនឯងរួច) ដូចជា ថាការពាក់ស្រោមដៃជាដើម។[21] ក៏ប៉ុន្តែ មេធាវីការពារក្តីយល់ស្របជាមួយសហព្រះរាជអាជ្ញា[22]ថា វាគ្មិនមិនចាំបាច់ពាក់របាំងកញ្ចក់ទេ ដោយហេតុថាមានកញ្ចក់ខណ្ឌចែករវាងអ្នកដែលមានវត្តមាន និងនៅចំពោះមុខអ្នកឈរនិយាយ។ នៅចុងបញ្ចប់ មេធាវីការពារក្តីមានបំណងសុំតុលាការកំពូល មេត្តាយកចិត្តទុកដាក់លើការលៃលកប្រើប្រាស់ពេលវេលាចាំបាច់ក្នុងម៉ោងសម្រាកចន្លោះពេលធ្វើ សវនាការ ដើម្បីសម្លាប់មេរោគ និងបើកឱ្យមានខ្យល់ចេញចូលក្នុងបន្ទប់សវនាការ។

## ផ្នែកទី៣. ការកត់សម្គាល់ពាក់ព័ន្ធការកំណត់កាលបរិច្ឆេទសវនាការ

២៧. មេធាវីការពារក្តីហាក់ដូចជាយល់ថា ការកំណត់កាលបរិច្ឆេទសវនាការនឹងអាស្រ័យជាពិសេសទៅ លើការវិវឌ្ឍនៃស្ថានភាពជម្ងឺរាតត្បាតកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។[23] ស្ថាប័នថ្នាក់ជាតិ និង ក្រោមជាតិទំនងជាអាចផ្តល់ព័ត៌មានអំពីការព្យាករណ៍ដែលបានធ្វើឡើងនៅថ្នាក់ជាតិ និងថ្នាក់មូល ដ្ឋាន។ ប្រការនេះអាចមានប្រយោជន៍ធ្វើឱ្យគេស្គាល់តុលាការកំពូល និងភាគីក្នុងរឿងក្តី។

២៨. មេធាវីការពារក្តីហាក់ដូចជាយល់ដែរថាចៅក្រមមួយរូបនឹងចូលរួមសវនាការពីចម្ងាយពីទ្វីបអឺរ៉ុប។ លើសពីនេះទៀត សមាជិកនៃការិយាល័យសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីដែលមិន អាចមកបន្ទប់សវនាការ ក៏នឹងចូលរួមពីចម្ងាយផងដែរ។ មេធាវីការពារក្តីយល់ស្របជាមួយភាគី ផ្សេងៗទៀតថា ការធ្វើតេស្តបច្ចេកទេសត្រូវតែធ្វើឱ្យបានលើសពីមួយសប្តាហ៍មុនពេលសវនាការ ដើម្បីឱ្យសវនាការដំណើរការទៅមុខបានរលូន។

---

[21] របាយការណ៍ ទំព័រ ៦ ERN 01669048។

[22] សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៨។

[23] សូមមើលខាងលើ កថាខណ្ឌ ១។

២៩. មួយវិញទៀត ដូចដែលមេធាវីការពារក្តីបានបញ្ជាក់រួចមកហើយ[24] មេធាវីអន្តរជាតិត្រូវចំណាយពេលមួយខែក្នុងការធ្វើដំណើរដើម្បីចូលរួមសវនាការតែមួយសប្តាហ៍ ដោយសារចត្តាឡីស័កពេលមកដល់ប្រទេសកម្ពុជា និងពេលត្រឡប់ទៅដល់ប្រទេសខ្លួនវិញ។ ដោយហេតុមានធុរៈក្នុងវិជ្ជាជីវៈរបស់ខ្លួន មេធាវីការពារក្តីអន្តរជាតិ អាចទំនេរតែចាប់ពីថ្ងៃទី០២ ខែសីហា រហូតដល់ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២១ តែប៉ុណ្ណោះ (កាលបរិច្ឆេទនៃវិស្សមកាលតុលាការ) ។ ដូច្នេះ មេធាវីការពារក្តីអន្តរជាតិអាចមកចូលរួមសវនាការដែលគ្រោងធ្វើនៅ សប្តាហ៍ថ្ងៃទី១៦ ខែសីហា។ ប្រសិនបើសវនាការមិនអាចធ្វើបាននៅសប្តាហ៍នេះទេ ជាជម្រើសចុងក្រោយ មេធាវីការពារក្តីអន្តរជាតិ អាចចូលរួមពីចម្ងាយ ក្នុងសប្តាហ៍មួយទៀតក្នុងខែសីហាដដែល។ នៅក្នុងករណីនេះ មេធាវីការពារក្តីអន្តរជាតិនឹងសម្របខ្លួនទៅតាមកាលវិភាគដែលកំណត់ដោយតុលាការកំពូល។ ប៉ុន្តែ រាល់ពេលសម្រាកចន្លោះម៉ោងសវនាការគួរតែផ្តល់លទ្ធភាពដល់ក្រុមការងារមេធាវីដើម្បីពិភាក្សាគ្នា។ ទន្ទឹមនឹងនេះ តុលាការកំពូលគួរគប្បីបង្កលទ្ធភាពឱ្យមេធាវីការពារអាចពិភាក្សាជាសម្ងាត់ជាមួយ ខៀវ សំផន (តាមរយៈការប្រើប្រព័ន្ធដែលមានស្រាប់ នៅក្នុងបន្ទប់ឃុំខ្លួនបណ្តោះអាសន្ននៅក្រោមបន្ទប់សវនាការ និងនៅក្នុងមន្ទីរឃុំឃាំង) ។ បើសវនាការត្រូវលើកទៅពេលក្រោយ វានឹងបង្កភាពស្មុគស្មាញខ្លាំងក្នុងការសម្របសម្រួលរកពេលវេលាទំនេររបស់ភាគីទាំងអស់។

៣០. ទោះយ៉ាងណាក្តី កាលបរិច្ឆេទសវនាការថ្មីត្រូវតែត្រូវបានជូនដំណឹង ដោយភ្ជាប់ព័ត៌មានលម្អិតឱ្យច្រើនបំផុតទៅតាមដែលអាចធ្វើទៅបាន ដើម្បីសម្រួលដល់ការរៀបចំចាំបាច់ និងការត្រៀមលក្ខណៈរបស់ភាគី។ លើសពីនេះទៀត តុលាការកំពូលត្រូវប្រញាប់បញ្ជូនសំណួររបស់ខ្លួនទៅភាគីទាំងអស់ ហើយដែលសំណួរទាំងនេះមិនពាក់ព័ន្ធនឹងការយល់ឃើញអំពីរឿងក្តីរបស់ចៅក្រមនោះទេ ប៉ុន្តែវាមានសារៈសំខាន់សម្រាប់ការត្រៀមលក្ខណៈរបស់ភាគី ជាពិសេសគឺសម្រាប់មេធាវីការពារក្តីដែលមិនត្រឹមតែត្រូវឆ្លើយតបនៅក្នុងពេលសវនាការប៉ុណ្ណោះទេ គឺថែមទាំងត្រូវបែងចែកការងារក្នុងក្រុមឡើងវិញ ក្នុងខណៈដែលម្នាក់ៗបានត្រៀមប្រធានបទខ្លួនរួចទៅហើយ ដោយហេតុថាបុគ្គលិកមេធាវីការពារក្តី ក៏នឹងត្រូវកាត់បន្ថយនៅថ្ងៃទី៣១ ខែឧសភា។ ការកាត់បន្ថយបុគ្គលិកនេះក៏ជះឥទ្ធិពលលើផែនការការងារដែលមេធាវីការពារក្តីត្រូវបញ្ជូនទៅការិយាល័យរដ្ឋបាលរៀងរាល់ខែ ហើយដែលម៉ោងធ្វើការបម្រុងទុកអាស្រ័យនឹងផែនការការងារនេះ។

[24] សេចក្តីសង្កេតរបស់ក្រុមមេធាវីការពារក្តី បន្ទាប់ពីសំណើសុំលើកពេលសវនាការលើបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២១ ឯកសារ **F61/1** កថាខណ្ឌ ៩។

៣១. **__អាស្រ័យហេតុនេះ__** មេធាវីការពារក្តីស្នើសុំអង្គជំនុំជម្រះតុលាការកំពូលមេត្តា÷

- **ចាត់** វិធានការណ៍ចាំបាច់ទាំងអស់ ដើម្បីឱ្យ ខៀវ សំផន មានវត្តមាននៅក្នុងបន្ទប់សវនាការសម្រាប់រយៈពេលពេញមួយសវនាការ។ ក្នុងករណីមិនអាចធ្វើបាន សូមមេត្តា **អនុញ្ញាត** ឱ្យគាត់ចូលក្នុងបន្ទប់សវនាការយ៉ាងហោចណាស់សម្រាប់ធ្វើសេចក្តីថ្លែងចុងក្រោយរបស់គាត់។
- **ពិចារណា** លើវិធានការណ៍បង្ការបន្ថែមដែលស្នើដោយមេធាវីការពារក្តី និងលើភាពទំនេររបស់មេធាវីអន្តរជាតិ។
- **បញ្ជូន** កាលបរិច្ឆេទថ្មីនៃសវនាការ (ក៏ដូចជាកាលវិភាគនៃការពិភាក្សាដេញដោល ដោយមានបញ្ជាក់អំពីប្រធានបទ និងរយៈពេលអន្តរាគមន៍) ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ទោះជាក្រៅផ្លូវការក៏បានដែរ។
- **បញ្ជូន** សំណួររបស់ខ្លួនទៅភាគីនានាឱ្យបានលឿនបំផុត ទោះជាមិនផ្លូវការក៏បានដែរ។

| | | |
|---|---|---|
| មេធាវី **គង់ សំអុន**<br><br>មេធាវី **Anta GUISSÉ** | ទីក្រុងភ្នំពេញ<br><br>ទីក្រុងប៉ារីស | |